ការបង្ហាញ សាច់ដុំ

ការបង្ហាញ សាច់ដុំ

ការចាប់ខ្លួន លោក ញ៉ីក ប៉ុនឌាយ និង សួន សេរីរដ្ឋា គឺជា ការ បង្ហាញ សាច់ដុំ របស់ លោក ហ៊ុន សែន ដែលវា គ្មានសារៈ ប្រយោជន៍ អ្វីបន្ទិចបន្តួចសោះ ដល់ខ្លួនឯង ព្រោះ វាជា ទង្វើ បញ្ជាក់ នូវ ភាពមិនទាន់ទុំកំនិត ហើយ វាមាន រូបភាព ដូចជា ការរំជើបរំជួល ក្នុងជួរ ពួកមនុស្សពាលា មាន នាមបញ្ញាតិ ថា ‹បងធំ-បងតូច› តែប៉ុណ្ណោះ។ នរណាក៏គេដឹងថា ជនរងគ្រោះ ទាំងពីរ សុទ្ធជា ឧបករណ៍ នៃ ល្បិចខូច របស់លោក ហ៊ុន សែន យកមកប្រើប្រាស់ គ្រប់នាកាល ល្អ ឬ អាក្រក់ តាមតែចិត្តចង់ បាន ដូចជា ការបំបាត់មានៈចេញ (défoulement) របស់ បងធំ ខឹងនឹង បងតូច។ មែនទែន ការបង្ហាញ សាច់ដុំ នេះ ជា សញ្ញាលក្ខ នៃ ទុរពល នៃ កម្លាំង សាច់ដុំ ខ្វះ អមោហៈ[1] គឺថា បើ ជនណា គ្មានហិរិ[2] កម្លាំងសាច់ដុំ របស់ជននោះ វាគ្រាន់តែជា ប ដិក្ខិត[3] នៃសភាវគតិ សុទ្ធសាត។ ដូច្នេះ កម្លាំងសាច់ដុំ អ៊ីហ្នឹង មិនមែន ជា កម្លាំងតិរច្ឆាន ទេឬ ?

សូមនិស្សរ្ជយ របស់ជនរងគ្រោះទាំងពីរនឹងលោក ហ៊ុន សែន គឺ ដូច ចៀម សូមនិស្សរ្ជយនឹងខ្លា អត់អាហារ នោះឯង។ លោក

---

[1] អមោហៈ ; équilibre mentale ou jugement droit។

[2] ហិរិ, សេចក្ដីខ្ជាស់នឹងអំពើអាក្រក់។

[3] បដិក្ខិត, ដែលធ្វើដោយឥតគិត, réflexe។

ការបង្ហាញ សាច់ដុំ

ញ៉ីក ប៉ុនណៃ សុខចិត្តទទួលកំហុស, លោក ស្ងួន សេរីរដ្ឋា សូមលាលែងពីតំណែង ប្រធានគណបក្សអំណាចខ្មែរ គឺ សុទ្ធជា កញ្ចក់ឆ្លុះបង្ហាញ នូវ ទុក្ខភ័យ របស់លោក ទាំងពីរ ក្នុងទ្រុងខ្លា នោះ ឯង ព្រោះថា ប្រព័ន្ធតុលាការ នៅស្រុកខ្មែរ វាជា ទំនៀមបោរោណានុបោរាណ[4] នៃ ប្រព័ន្ធ របបផ្តាច់ការ គឺ យុត្តិធម្ម របស់អ្នកខ្លាំង ជា អធិបតី នៃ តុលាការផង ជា ជនដើមចោទផង។ បើអ្នកជាប់ចោទ ប្រកែកនឹង អ្នកខ្លាំង វានាំអោយ កំហុស ជា ទោសកុកលហុ ទៅជា ទោសកុកឧក្រិដ្ឋ តែបើ ចារី (auteur) សារភាពទទួលខុស គេអាចនឹងព្យួរទោស តែ ចារីនោះ នៅតែ ទុកជាជនដែលគួរដាក់ទណ្ឌកម្ម[5] បានគ្រប់ពេលវេលា ព្រោះវា គ្មាន អាជ្ញាយុកាល នៃបទល្មើស[6] ដូចជាករណី លោក កឹម សុខា ដែលគាត់ កំពុងស្ថិតនៅក្នុង ការបង្ហង់ប្រតិបត្តិទោស[7] ជា ដរាបរៀងទៅ។ យុត្តិធម៌ បែបនេះ ជា របៀបចាត់ការ (mode opératoire) របស់លោក ហ៊ុន សែន មិនមែន សំរាប់រក សេចក្តីសុខសាន្តខាងក្នុងរដ្ឋ[8] ឬ សន្តិភាពសង្គម នោះទេ តែ ជា ការ បង្ហាញសាច់ដុំ ក្នុង ហាន: ជា បងធំ នៅក្នុង ក្រុម មាហ្ហ៊ីយ៉ា តែ ប៉ុណ្ណោះ។

---

[4] បោរោណានុបោរាណ, បុរាណមុនៗនិងបុរាណជាលំដាប់បន្ទាប់តៗមក។

[5] Des personnes punissables។

[6] De la prescription de l'infraction។

[7] ការបង្ហង់ប្រតិបត្តិទោស ; sursis à l'exécution des peines។

[8] សេចក្តីសុខសាន្តខាងក្នុងរដ្ឋ ; la sûreté intérieure de l'Etat។